[*អ្នកសម្ភាសៈ សាយ តុលា*- អ្នកផ្តល់បទសម្ភាសន៍ៈ គើយ រដ្ឋា]
[*Interviewer: Tola Say*. Interviewee: Koeuy Reatha]

[00:00]

ជម្រាបសួរ! ខ្ញុំបាទឈ្មោះ គើយ រដ្ឋា។ ឈ្មោះក្រៅរបស់ខ្ញុំគឺ «គន់»
ដែលជាកូនរបស់លោកតា គើយ។ ឈ្មោះពេញរបស់ឪពុកខ្ញុំគឺ ម៉ុង គើយ។
ខ្ញុំគឺជាក្រុមគ្រួសាររបស់អ្នកធ្វើអង្កួចនៅក្នុងខេត្តសៀមរាប។
ដោយសារតែមានអង្គការមកពីចក្រភពអង់គ្លេសបានបង្ហាញនូវរូបភាពអង្កួចមួយ
ដែលមានរូបរាងបែបនេះដល់ខាងក្រុមគ្រួសារខ្ញុំ។
គាត់បានស្រាវជ្រាវរកអ្នកធ្វើអង្កួចនេះ។
Hello! My name is Koeuy Reatha. My nickname is Kun, and I’m a son of Ta Koeuy. My father’s full name is Mong Koeuy. I am a son of an Angkuoch-maker family based in Siem Reap province. A research team from an organisation, the British Museum, showed my family a picture of an Angkuoch. They are looking for the maker of this Angkuoch.

[00:39]

តាមរយៈរូបភាពអង្កួចនេះ ខ្ញុំសន្និដ្ឋានថាវាជាអង្កួចរបស់ឪពុកខ្ញុំ
ដោយសារលក្ខណៈនៃអង្កួចនេះ ដូចនឹងរាងអង្កួចដែលឪពុកខ្ញុំធ្វើផ្ទាល់ដៃ។
អង្កួចដែលខ្ញុំធ្វើសព្វថ្ងៃនេះ មានសិស្សជាច្រើនបានមករៀនពីឪពុកខ្ញុំ។
ពួកគាត់រៀនធ្វើអង្កួចដែលមានលក្ខណៈបែបនេះ
គឺអង្កួចដែលមានក្បាលរាងមូលខាងលើ។ សម្រាប់រង្វាស់ខាងលើនេះ
ឪពុកខ្ញុំធ្លាប់បង្រៀនឱ្យខ្ញុំវាស់ខ្នាតដៃ។
From this picture, I assume that the instrument is made by my father because the appearance of this Angkuoch is the same as my father’s Angkuoch. The type of Angkuoch that I make, there were many people who came to learn how to make that type of Angkuoch from my father. They learned to make the Angkuoch with this shape, in which the head of Angkuoch is round. For the measurement right here, my father told me to measure that with my fingers, like this [demonstrates].

[01:20]

ហើយនៅកណ្តាលនេះ ពួកយើងប្រើធ្នាប់ដៃបន្ត។ ពេលខ្លះបីធ្នាប់ដៃ
ឬពីរធ្នាប់ដៃកន្លះ។ ប៉ុន្តែអ្វីដែលឪពុកខ្ញុំធ្លាប់ធ្វើពីមុន
គាត់ចូលចិត្តធ្វើផ្នែកកណ្តាលនេះវែង។ វែងជាងពួកខ្ញុំធ្វើសព្វថ្ងៃបន្តិច! ជាក់ស្តែង
ឪពុកខ្ញុំចូលចិត្តធ្វើបែបហ្នឹង។ ប៉ុន្តែក្រោយមក ពួកខ្ញុំចូលចិត្តធ្វើរបៀបនេះ។
វារាងខ្លីជាង និងតូចជាងរបស់ឪពុកខ្ញុំបន្តិច។

And for this middle part, we still measure the length with the span of our fingers – stretching between the thumb and third finger or between thumb and half of the third finger. But my father liked to make this middle part a bit longer, a bit longer than we do these days. Actually, my father liked to make it long like this. But later on, we prefer to make it like this [indicates instrument in hand]. It is shorter and smaller than my father’s.

[01:49]

ដោយសារអ្នកគ្រូ(សំដៅដល់ ស.ត) បានប្រាប់ថា
អង្កួចនេះត្រូវបានទុកក្នុងសារៈមន្ទីរនៃចក្រភពអង់គ្លេស ខ្ញុំពិនិត្យហើយពិនិត្យទៀត
ហើយខ្ញុំនៅតែសន្និដ្ឋានវាជាអង្កួចរបស់ឪពុកខ្ញុំ។ ពីព្រោះម៉ូដនេះ

កាលពីដើមឪពុកខ្ញុំបានពន្យល់ប្រាប់ថា ជីតាខ្ញុំដែលជាអ្នកធ្វើ
ដោយនៅផ្នែកកណ្ដាលនៃអង្កួចគឺវាមានដោះមួយដែលមានរាងបែបនេះ។ នេះហៅថា
«ដោះអង្កួច»។
Because you [Tola] told me that this instrument has been kept in the British Museum, I have checked again and again, and I still believe that it is made by my father, because of the style. My father told me earlier that my grandpa had been an Angkuoch maker too. However, in the middle part of this Angkuoch [in my hand], it has a ‘breast’ like this. This is the ‘Angkuoch’s breast’.

[02:23]

កាលពីមុន កាលពីដែលលោកតាខ្ញុំធ្វើ ពុកខ្ញុំថា គាត់មិនធ្វើដោះបែបនេះទេ។
គាត់បង្កើតដោះនេះតាមក្រោយ។ ហើយអង្កួចដែលមានលក្ខណៈបែបនេះ
គាត់ជាអ្នកធ្វើដោយដៃផ្ទាល់ ហើយគាត់បានបង្រៀនខ្ញុំ បងប្រុសខ្ញុំ
និងប្អូនប្រុសខ្ញុំចំនួនពីរនាក់។ សរុបទៅ ក្រុមគ្រួសារខ្ញុំចេះធ្វើបួននាក់។
ហើយពួកម៉ាករបស់ខ្ញុំក៏បានរៀនពីឪពុករបស់ខ្ញុំដែរ។ ពូជី
និងមនុស្សបួននាក់ទៀតមកពីស្រះស្រង់ដែលខ្ញុំមិនបានចាំឈ្មោះអស់មករៀនពីឪពុ
កខ្ញុំ។ គាត់បានរក្សាម៉ូដនេះ ដោយកែប្រែតិចតួចប៉ុណ្ណោះ។
My father told me that my grandpa did not make it like this, when he made Angkuoch. My father later invented this breast. He taught me, my older brother and my two younger brothers to make it too. In total, there are four in my family who make Angkuoch. My friend also learned from my father. Uncle Chi [Krak Chi] and other other four people whose names I forget also came to learn from my father. They followed my father’s style, just slightly changed it.

[03:03]

ហើយនៅខាងឃុំខ្ញុំនេះ នៅឃុំព្រះដាក់ មានអ្នករៀនផ្សេងទៀតដូចជា៖ មេត្តាក់
និងអន្ទិតកុក។ ពួកគាត់ក៏បានរៀនពីឪពុកខ្ញុំដែរ ប៉ុន្តែពេលដែលគាត់ធ្វើ
គាត់ច្នៃម៉ូដផ្សេងៗពីនេះបន្តិច។ ដោយពិនិត្យ និងយោងតាមរូបភាពអង្កួច
ខ្ញុំប្រាកដថា អង្កួចនេះជាអង្កួចរបស់ឪពុកខ្ញុំ។ ដែលកន្លងមកខ្ញុំមិនដឹងថា
ជនបរទេសរូបណាទេដែលយកវាទៅដាក់នៅចក្រភពអង់គ្លេស។ ពីព្រោះថា អង្កួច
ទំហំអង្កួច និងម៉ូដរបស់អង្កួចនេះ ខ្ញុំមើលទៅ
វាជាប្រភេទដែលឪពុកខ្ញុំច្រើនធ្វើជាប្រចាំ។ដោយសារឪពុកខ្ញុំចេះធ្វើអង្កួចតាំងពីពេ
លដែលគាត់ចេះកាន់ក្រប៊ិត។ ហើយពួកខ្ញុំក៏ចេះបន្តមករហូត។ តែបច្ចុប្បន្ន
ខ្ញុំមិនសូវបានធ្វើ ដោយសារខ្ញុំមានការងារធ្វើផ្សេង
ប៉ុន្តែខ្ញុំអាចធ្វើបានមួយរយភាគរយ។ ឱ្យតែចង់បានម៉ូដបែបណា
ខ្ញុំអាចធ្វើបានតាមតម្រូវការរបស់ភ្ញៀវ។
And in this commune, Preah Dak commune, there were other people who came to learn too, such as Metak and Kok. They also learned from my father, however, they have invented quite a different style. By checking this picture, I am very sure that this Angkuoch was made by my father. But so far, I have not known any foreigner who took his Angkuoch to the British Museum. The Angkuoch’s shape and style is the style that my father always made because my father started to make Angkuoch from the time when he could hold a knife. Then later we continued to learn from him. But now, I do not have so much time to make Angkuoch because I have other work to do. However, I can still make them a hundred percent. Whatever style the customer wants, I can make it.

[04:03]

*អម្បាញ់មិញ បងបានប្រាប់ពីទំហំបែបនេះ។ អញ្ចឹង ខ្ញុំចង់ឱ្យបងជួយបញ្ជាក់ថា តើកាលពីឪពុកបងធ្វើ តើគាត់ធ្វើប្រវែងប៉ុន្មាន? ប៉ុណ្ណេះ? ខ្ញុំចង់ដឹងវាមានប្រវែងប៉ុន្មានឱ្យប្រាកដ?*
*Just before, you referred to the length of this [indicates top carved section of the Angkuoch]. Could you please tell me how long did your father make it? I want to know how long it is specifically.*

ជាប្រចាំ ឪពុកខ្ញុំតែងដាក់ដៃបែបនេះនៅលើក ហើយគាត់ច្រើនប្រើដៃបីធ្នាប់។ ចំណែកនៅលើត្ដូអណ្ដាត និងក្រប គាត់ច្រើនប្រើបីធ្នាប់ និងថែមបន្ដិចទៀត។ តាមទំហំដៃរបស់គាត់ គាត់ថែមបន្ដិចទៀត។ ហើយជាទូទៅ ទំហំកន្លែងនេះ និងទំហំកន្លែងនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នា។
Normally, my father always placed his hand like this on the neck of Angkuoch and he measured the width from his first to his third finger. As for the lamella and 'cover', he always used the width of his first three fingers and plus a bit more. To the width made by those fingers, he added a bit. And normally, the length here and here [indicates] is the same.

[04:49]

បើតាមពួកខ្ញុំធ្វើក្រោយ ពួកខ្ញុំច្រើនធ្វើកន្លែងនេះខ្លី។ បើនិយាយពីប្រវែងពីកន្លែងនេះ មកកន្លែងនេះ ឪពុកខ្ញុំច្រើនធ្វើខ្នាតវាឱ្យស្មើគ្នា ឬខុសគ្នាតិចតួច។ ខ្ញុំចង់និយាយពីកន្លែងនេះមកត្រឹមនេះ និងពីកន្លែងនេះ មកដល់ត្រឹមនេះ។ ឪពុកខ្ញុំច្រើនធ្វើលក្ខណៈបែបហ្នឹង។
But what we did later is make the part here a bit shorter [indicates]. If we are talking about the length from here to here [indicates], my father made it the same length or only slightly different. I want to clarify that that is from here to here. My father always did it like that.

[05:09]

ហើយលក្ខណៈអង្កួចគាត់ធ្វើម្យ៉ាងទៀត ខ្ញុំតែងចំណាំលក្ខ័ណរបស់គាត់ បើមានជាប់ថ្នាំងត្រង់កន្លែងកន្ទុយតិចៗ ភាគច្រើនវាជាអង្កួចដែលគាត់តែងតែធ្វើ ព្រោះគាត់ថា បើទុកថ្នាំងនោះ អង្កួចអាចនៅមាំល្អ។ គាត់សុខចិត្តចំណាយពេលបិតយូរ។ ពេលខ្លះ គាត់ក៏ធ្វើមិនបានដែរ ដោយសារវាអាស្រ័យតាមថ្នាំងឬស្សីវែង ឬខ្លី។
And another remark on something I have noticed is that if there was a bamboo internode [between two nodes], he [my father] liked to use that part for the tail of the Angkuoch because he said if we keep that internode of the bamboo, an Angkuoch can last for a long time. He was willing to spend a longer time to carve it then. He could not make all Angkuoch with an internode, because not every piece of bamboo had an internode.

[05:33]

សម្រាប់អង្កួចនេះ ខ្ញុំមើលទៅប្រវែងដែលអ្នកគ្រូប្រាប់ ដោយសារខ្ញុំមិនបានឃើញផ្ទាល់ ខ្ញុំមើលទៅប្រវែងរបស់វា ខ្ញុំគិតថាវាប្រាកដជាខ្នាតរបស់គាត់។ ព្រោះកន្លងមក គាត់ចូលចិត្តថែមបន្ដិចត្រង់កន្លែងនេះ និងកន្លែងនេះ។ បើមើលទៅរាងរបស់វាវិញ ខ្ញុំអាចទាញសន្និដ្ឋានបាន ដោយសារតែកូនសិស្សដែលមករៀនពីគាត់តែងតែធ្វើរាងរបៀបនេះរហូត។ ហើយអ្នកណាក៏ដឹងដែរថា ឪពុកខ្ញុំធ្វើអង្កួចនៅសៀមរាប។ នៅខេត្តសៀមរាប អ្នកណាក៏ដឹងដែរ។ ចំពោះអ្នកផ្សេងដែលខ្ញុំធ្វើម៉ូដផ្សេងៗទៀត គ្រួសារខ្ញុំមិនសូវបានធ្វើទេ។ ដូចអ្នកគ្រូបានបង្ហាញខ្ញុំនូវម៉ូដផ្សេងៗនោះ

គ្រួសារខ្ញុំធ្វើតិចតួចប៉ុណ្ណោះ។ ពួកយើងធ្វើពេលដែលគេត្រូវការ។ បើធ្វើជាប្រចាំ ពួកខ្ញុំធ្វើម៉ូដនេះ។
As for this Angkuoch [indicates the British Museum instrument], since you have told me about the length, I am sure that is the length my father used, although I cannot see this Angkuoch directly. Looking at this shape, I make an assumption, because his students always make Angkuoch like this. Everyone in Siem Reap knows that my father was Angkuoch maker. Everyone from Siem Reap knows. You have shown me other Angkuoch types; my father did not make many of those. We did those just when there were orders. As for the usual making, we always made this type.

[06:18]

*មួយទៀតខ្ញុំចង់ឱ្យបងប្រាប់អំពី... ដោយសារបងទើបតែប្រាប់ថា ឪពុកបងធ្វើឱ្យមានដោះពីលើអង្កួច។ ចុះពីមុន តើគេធ្វើអង្កួចបែបណា?*
*Another thing I want to ask is ... You just told me that your father liked to make Angkuoch with the breast. How did people make the instrument before?*

អង្កួចមួយប្រភេទទៀត ឪពុកខ្ញុំប្រាប់ថា កាលពីពេលដែលតាខ្ញុំធ្វើ នៅលើអណ្តាតអង្កួចនេះ គាត់មិនដាក់ឬស្សីទុកបែបនេះទេ។ គាត់ចិតអស់។ ចិតឡើងស្មើ! ប៉ុន្តែគាត់បិតក្រមួនឃ្មុំជំនួសវិញ។ ឬពេលខ្លះ គាត់មិនបិតទេ។ ប៉ុន្តែក្រោយមក ឪពុកខ្ញុំថា គាត់ច្នៃដោះនេះដោយខ្លួនឯង។ ពេលដែលគាត់សាកល្បងធ្វើបែបនេះ អង្កួចនៅតែលឺ។ គាត់មិនមែនច្នៃថ្មីៗទេ។ គាត់បានច្នៃយូរហើយ។ ពេលដែលគាត់ស្លាប់ គាត់មានអាយុ៧៨ឆ្នាំ។ អញ្ចឹង គាត់ប្រហែលជាកើតក្នុងអំឡុងឆ្នាំ១៩៣០ជាង។ ទាក់ទងនឹងក្បាល គាត់តែងតែបង្រៀនពួកខ្ញុំឱ្យចិតបែបនេះ។ របៀបនៃការចិតក្បាលនេះ ខ្ញុំមិនចេះតែចិតតាមចិត្តបាននោះទេ។ ខ្ញុំត្រូវចិតវាឱ្យសមជាមួយអណ្តាត ដូចនេះវាអាចលឺសម្លេងពេលដែលរលាស់ទៅ។ បើចិតមិនត្រូវជាមួយអណ្តាត...
Another type of Angkuoch - my father told me that when my grandpa made Angkuoch, he did not carve the bamboo like this. He carved until it became flat. Carving until it became flat! And so he used beeswax instead [to make the ‘breast’]. Sometimes he did not put wax on. But later on, my father created the breast here by himself. When he first tried to make it [like this], he found the Angkuoch could still generate a sound. He did not create that recently. He created it a long time ago. When he passed away [in 2012], he was 78 years old. So he was probably born in around the 1930s. Relating to the head of the Angkuoch, he always instructed us to carve it like this. We couldn’t carve in whatever way we wanted. We had to make it fit with its lamella so then it can vibrate when we play. If it does not fit with lamella...

[07:48]

អង្កួចនេះ បើចង់ឱ្យវាលឺមែនទែន ពេលដែលចិតក្បាល យើងត្រូវកោសអណ្តាត។ ចិតរួចកោស! ប្រសិនបើក្បាលនេះមិនសូវទន់ល្អ យើងត្រូវកោសអណ្តាតនេះ។ ត្រូវសម្រួលក្បាល! ជួនកាល ក្បាលតូច ឬធំ បើកែសម្រួលតែកន្លែងនេះ វានឹងមិនលឺសម្លេងតែម្តង។
If we wanted the Angkuoch to have a loud sound, we carved its head, then we had to scrape the lamella. Carve and then scrape! If this head is not soft enough, we have to scrape its lamella. Revamp the head of the Angkuoch! Sometimes the head of the Angkuoch is small, so if we only work on it here, it will definitely not release a sound.

[08:07]

បើមើលពីទំហំ និងប្រវែងរបស់អង្កួចនេះ
ភាគច្រើនឪពុកខ្ញុំធ្វើត្រង់អណ្តាតនេះវែងជាងអ្វីដែលពួកខ្ញុំធ្វើពេលបច្ចុប្បន្ន។
ពួកខ្ញុំធ្វើពេលបច្ចុប្បន្ននេះមិនសូវវែងទេ។ គាត់ភាគច្រើនធ្វើវែង
ហើយអណ្តាតដែលគាត់ធ្វើមានរាងមូល។ អ្វីដែលពុកខ្ញុំធ្វើធំជាងរបស់ខ្ញុំបន្តិច។
វាមិនសូវតូចបែបនេះទេ (ដូចអង្កួចដែលគាត់កំពុងកាន់)។
នេះជាអ្វីដែលពួកម៉ាកខ្ញុំធ្វើរាល់ថ្ងៃ។ វាជារបស់តូក។
Considering the shape and length of this Angkuoch, my father mostly made a longer lamella than us. What we make is not so long. He mostly made it long and the shape of lamella was round. My father's Angkuoch is a bit longer than mine. It is not small like this [indicates instrument he is holding]. This one is made by my friend. His name is Tok.

[08:33]

*មួយទៀត!តើបងគិតថា ឪពុកបងចាប់ផ្តើមធ្វើអង្កួចតាំងពីអាយុប៉ុន្មាន?*
*ហើយអង្កួចក្នុងរូបនេះប្រហែលជាអាយុប៉ុន្មានហើយ?*
*One more! How old do you think your father was when he started to make Angkuoch? And how old is the Angkuoch in this picture?*

បើតាមគាត់ប្រាប់ខ្ញុំ គាត់ថា
គាត់ចេះធ្វើអង្កួចតាំងពីពេលដែលគាត់ចេះកាន់កាំបិត។ មានន័យថា
ពេលដែលគាត់អាយុដប់ឆ្នាំជាង ហើយគាត់ចាប់ផ្តើមកាន់កាំបិតបាន
គាត់ក៏ចាប់ផ្តើមធ្វើតែម្តង។ ហើយដែលគាត់ចេះធ្វើនេះ
គាត់មិនបានរៀនពីអ្នកណាទេ គឺគាត់រៀនពីតារបស់ខ្ញុំ។ តារបស់ខ្ញុំឈ្មោះ មុង។
គាត់ជាតារបស់ខ្ញុំបង្កើត។ គាត់តែងប្រាប់ឪពុកខ្ញុំថា ពុកខ្ញុំត្រូវរៀនឱ្យចេះ
ព្រោះវាជារបស់យើង។ គាត់តែងតែប្រាប់បែបនេះ។
Based on what he told me, he said that he started to make Angkuoch since the time when he could hold a knife. That means he started to make Angkuoch when he was about ten years old. He learned from no one but my grandpa. My grandpa's name is Mong. He is my grandpa by blood. He always told my father he must learn to make Angkuoch because it is our instrument. He always said this.

[09:16]

ទាក់ទងនឹងអាយុកាលរបស់អង្កួចនេះ បើមើលតាមរូប ខ្ញុំមិនទាន់ហ៊ានសន្និដ្ឋានទេ។
ប៉ុន្តែ អង្កួចនេះប្រហែលជាយូរហើយ។ វាអាចធ្វើមុនពេលដែលខ្ញុំកើត។
អង្កួចនេះមានអាយុកាលមុនខ្ញុំកើត។ បើមើលទៅលើសាច់អង្កួច... បើតាមខ្ញុំមើល
ខ្ញុំគិតថាឫស្សីដែលធ្វើអង្កួចនេះមានលក្ខណៈចំណាស់។ មានន័យថា
វាជាប្រភេទឫស្សីចាស់។ ព្រោះខ្ញុំដែលជាអ្នកធ្វើសារក្រោយ
មិនសូវបានប្រើឫស្សីចាស់ទេ។ ឱ្យតែឫស្សីល្មមអាចធ្វើបាន ខ្ញុំយកមកធ្វើ។ បើឪពុកខ្ញុំ
គាត់ច្រើនប្រកាន់យកឫស្សីចាស់។ ឫស្សីចាស់ឬថ្មី ខ្ញុំគ្រាន់តែក្រឡេកអាចដឹង។
ឫស្សីខ្លះមិនអាចធ្វើលឺទេ។ ឫស្សីសាច់ត្រឹមិនអាចធ្វើលឺទេ។ គ្រាន់តែពុះឫស្សី
ខ្ញុំអាចដឹងថាវាអាចធ្វើលឺឬអត់។ ខ្ញុំអាចដឹងថា អង្កួចដែលធ្វើពីឫស្សីនោះនឹងលឺ។
ឫស្សីសាច់ត្រីអាចធ្វើលឺដែរ តែវាលឺមិនសូវល្អ។ វាចេញសម្លេងមិនរលាស់ល្អ។
Regarding the age of Angkuoch, from what I see, I cannot make any assumption. But it is probably old. It was probably made before I was born. It is probably older than me. If I look at the 'flesh' of the Angkuoch, it looks very old. I mean that old bamboo was used to make this instrument. Because I am a later maker, I do not really use old bamboo. As long as it can be used, I use it. As for my father, he used only old bamboo. I can immediately tell whether an Angkuoch is made from old or fresh bamboo. I can tell by just listening to the

sound of chopping. I can tell whether that Angkuoch could produce a sound. Bamboo with soft flesh can be used but it does not sound so good. It sound does not resonate well.

[10:28]

មួយចំណុចទៀតដែលខ្ញុំចង់បញ្ជាក់បន្ថែម នៅលើអង្គួចនេះ បើវាជារបស់ឪពុកខ្ញុំ គាត់ច្រើនតែក្រឡឹងនៅកន្លែងនេះ។ គាត់តែងក្រឡឹងមិនលើសពីប្រាំទេ។ គាត់តែងតែបួនត្រង់ពីរផ្នែកនេះ។ នៅកន្លែងនេះមួយ និងកន្លែងនេះមួយ! ខ្ញុំចង់និយាយថា នៅក្បែរអណ្ដាតមួយ និងកន្ទុយនេះមួយ។ ហើយការក្រឡឹងរបស់គាត់ ឪពុកខ្ញុំច្រើនក្រឡឹងមុតជ្រៅ ហើយត្រង់ស្អាត។ ពេលខ្លះគាត់ក៏មិនបានក្រឡឹងដែរ។ ពេលដែលគាត់ធ្វើក្រោយមកនេះ គាត់ក៏ក្រឡឹងដែរ។ រហូតមកដល់ពួកខ្ញុំក៏ក្រឡឹងដែរ។ មួយទៀត គាត់ចូលចិត្តឆ្លាក់រូបអង្គរកំពូលបី។ បើខ្ញុំមើលអង្គួចនេះ វាជាអង្គួចលាតជម្មតា។ វាមិនមានការក្រឡឹង។ អ្វីដែលខ្ញុំត្រូវបន្ថែមមានតែប៉ុណ្ណឹង។
Another point that I want to clarify is that, if this Angkuoch is made by my father... he liked to carve lines here. He liked to carve not more than five. He mostly made four lines here and four lines here. Here and here! I want to mention that this is next to lamella and tail. Also, his carved lines are deep and straight. Until now, we also carve lines. Also, he liked to draw Angkor Wat with three tops as his motif. But this Angkuoch seems empty. It does not have a motif. That is the thing I want to clarify.

*អរគុណ!*
*Thank you!*

[11:37 - END]